# ពិភេក៖ យុត្តិកម្មនៃឥរិយាបថសីលធម៌ក្នុងរឿងរាមកេរ្តិ៍

មានប្រភពនិងការបកស្រាយជាច្រើន អំពីរាមកេរ្តិ៍ដ៏វែងនេះ រួមទាំងសាច់រឿងឥណ្ឌាដើម ការបកប្រែ លំនាំតាម និងការកែច្នៃនៃសាច់រឿង ជាពិសេសនៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ឥណ្ឌាភាវូបនីយកម្ម។ អត្ថបទនេះ នឹងបង្ហាញត្រួសៗទៅលើតួអង្គពិភេកនិងគ្រួសាររបស់គាត់ ជាពិសេស នាង បុញ្ញកាយ (បញ្ញកាយ)។

ពិភេក ជាភាសាសំស្ក្រឹត «ពិភសណ» (*Wibhisana*)[១] និងជាយក្សពណ៌បៃតង គ្រូទាយ ប្អូនប្រុសនិងទីប្រឹក្សារបស់ក្រុងរាពណ៍ មុននឹងទៅបម្រើព្រះរាម។ ពិភេក ជាព្រះរាជបុត្ររបស់ព្រះចៅក្រុងលង្កា វិស្រវៈ (រាស្តាន) និងព្រះនាងសុកេសី (ឧទលា/រាជធីតា)។ ព្រះឥសូរបានឱ្យទៅពិភេកនូវកែវមនោហារាមួយ ដែលអាចធ្វើឱ្យពិភេកប្រមើលឃើញអនាគតបាន។ ពិភេក បានរៀបអភិសេកជាមួយនឹងនាងសុជតា ហើយបានបុត្រីមួយអង្គ គឺនាងបុញ្ញកាយ។ ក្រោយមក ពិភេកត្រូវបានក្រុងរាពណ៍និរទេស ទើបរត់ទៅនៅបម្រើព្រះរាម។ នៅចុងបញ្ចប់នៃរឿងរាមកេរ្តិ៍ ពិភេកក៏បានឡើងគ្រងរាជនៅនគរលង្កាបន្ទាប់ពីរាពណ៍បានស្លាប់។

មានរឿងសំខាន់មួយចំនួននៅក្នុងរឿងរាមកេរ្តិ៍ ដែលមានភាពប្លែកគ្នានៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ដូចជាដើមកំណើតរបស់ក្រុងរាពណ៍ ដែលជាលទ្ធផលនៃអសីលធម៌របស់មាតាបិតារបស់គាត់ ដូច្នេះបានត្រូវបណ្តាសាររបស់អាទិទេព ព្រោះវិស្រវៈ (ព្រះបិតា) បានបង្រៀនអាថ៌កំបាំងសិល្ប៍សាស្ត្រដល់សុកេសី (ព្រះមាតា)។[២]

ពិភេក ប្អូនប្រុសរបស់រាពណ៍ បានផ្តល់យោបល់ដល់រាពណ៍ឱ្យដោះលែងព្រះនាងសីតាពីការឃុំឃាំង ដែលធ្វើឱ្យរាពណ៍មានកំហឹងយ៉ាងខ្លាំង រួចហើយក៏បានជាក់ក្បាលពិភេកដែលធ្វើឱ្យពិភេករត់ទៅបម្រើព្រះរាម។ ក្នុងន័យនេះ ប្រជាជនឥណ្ឌូណេស៊ី គិតថាទោះបីជារាពណ៍អាក្រក់និងឃោរឃៅយ៉ាងណាក៏ដោយ ក៏ពិភេកមិនត្រូវរត់ទៅបម្រើព្រះ

[១] *Reamker* 1964: 3:6

[២] Sears (1986); Madoka Fukuoka 2015: 365).

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

រាមឡើយ ព្រោះធ្វើដូច្នេះមានន័យថាពិភេកក្បត់បងរបស់ខ្លួន។ ផ្ទុយពីនេះទៅវិញ យើងឃើញថា ប្អូនប្រុសរបស់រាពណ៍ឈ្មោះ កុម្ភការណ៌ បាននៅបម្រើបងរបស់ខ្លួនរហូតដល់ជីវិតចុងក្រោយ ស្លាប់នៅក្នុងសង្គ្រាមជាមួយនឹងកងទ័ពព្រះពន្លារបស់ព្រះរាម។ នៅក្នុងសាច់រឿងរបស់ កូសាសិ (Kosasih) រាពណ៍ បានសម្លាប់ពិភេក បន្ទាប់ពីពិភេកបានណែនាំគាត់ឱ្យដោះលែងព្រះនាងសីតាពីការឃុំឃាំង។ ហនុមាន បានរកឃើញសាកសពរបស់ពិភេក ហើយបានប្រគល់ឱ្យទៅកងទ័ពរបស់ព្រះរាម។ ព្រះរាមក៏បានបញ្ជាឱ្យហនុមានទៅរកឱសថទិព្វពីលើកំពូលភ្នំដើម្បីធ្វើឱ្យពិភេករស់រានមានជីវិតឡើងវិញ។[៣] ក្នុងរឿងនេះ កូសាសិ បកស្រាយថា ពិភេកមិនបានក្បត់រាពណ៍ឡើយ ដោយអះអាងថា គឺខាងព្រះរាមទេដែលបានផ្តល់ជីវិតដល់ខ្លួនដោយបានធ្វើឱ្យខ្លួនរស់រានមានជីវិតឡើងវិញ។[៤]

ដោយឡែក ក្រោយពីពិភេកបានរស់រានមានជីវិតឡើងវិញហើយ បុញ្ញកាយក៏បានជួបជុំនឹងបិតារបស់នាងវិញ។ នាងបុញ្ញកាយ ក៏បានទូលថ្វាយទៅព្រះរាមអំពីរឿងរ៉ាវសព្វគ្រប់ពាក់ព័ន្ធនឹងព្រះនាងសីតា។ បន្ទាប់មក ហនុមាន ក៏បានត្រកងនាងបុញ្ញកាយនៅនឹងដៃ ហៀរហោះនាំនាងទៅវិមានរបស់នាងវិញ។ នៅតាមផ្លូវធ្វើដំណើរនោះ ហនុមានស្រើបស្រាលនៅក្នុងចិត្តពន់ប្រមាណ ទ្រាំពុំបាន ក៏បញ្ចេញទឹកកាមធ្លាក់ទៅក្នុងសមុទ្រដែលផ្តល់កំណើតដល់បុត្រាមួយអង្គគឺ ទុគង្គា (Tugangga)។[៥]

## សេចក្តីស្នេហារវាងនាងបុញ្ញកាយនិងហនុមាន

បុញ្ញកាយ ជាបុត្រីរបស់ពិភេក ដូច្នេះនាងត្រូវជាក្មួយស្រីរបស់ក្រុងរាពណ៍។ នាងបុញ្ញកាយ ជាអ្នកស្មោះត្រង់និងតាមថែរក្សាព្រះនាងសីតាជារៀងរហូត។ នៅក្នុងសាច់រឿងនៃល្ខោនស្រមោលស្បែកតូចឥណ្ឌូណេស៊ី វ៉ាយ៉ាំងគូលិត (wayang kulit) នាងបញ្ញកាយត្រូវបានរៀបការជាមួយនឹងជម្ពូពាន ដោយត្រូវបណ្តាសាររបស់រាពណ៍ ព្រោះមានពេល

---

[៣] Kosasih 1975: 207–211

[៤] Sears 1996: 277–278

[៥] Kosasih 1975: 243

*មួយនោះ រាពណ៍មានបំណងប្រើល្បិចទៅលើព្រះនាងសីតា នៅពេលដែលព្រះនាងពុំព្រមស្តាប់គាត់។ រាពណ៍បានកាត់ក្បាលអ្នកទោសពីរនាក់ ហើយលើកឡើងបង្ហាញព្រះនាងសីតាថាជាព្រះកេសរបស់ព្រះរាមនិងព្រះលក្ស្មណ៍។ ព្រះនាងសីតា មានការសោកសៅយ៉ាងខ្លាំងចំពោះអំពើដ៏ឃោរឃៅរបស់រាពណ៍ ប៉ុន្តែនាងបញ្ចកាយបានដឹងពីការពិត ហើយបានទូលទៅព្រះនាងសីតាពីការពិតនោះ ដែលធ្វើឱ្យរាពណ៍មានកំហឹងក្រេវក្រោធយ៉ាងខ្លាំង ហើយបានដាក់បណ្តាសារឱ្យនាងបញ្ចកាយត្រូវរៀបការជាមួយនឹងស្វាចាស់មួយ គឺជម្ពូពាននេះឯង ហើយជាមួយគ្នានេះ បានបុត្រីមួយអង្គដែលនៅក្នុងរឿងមហាភារតយុទ្ធ ជាព្រះមហេសីរបស់ព្រះក្រឹស្នា៕*

## *ឯកសារពិគ្រោះ*


Fukuoka, Madoka. (November 27, 2015). “Reinterpretation of the Ramayana in Indonesia: A Consideration of the Comic Works of R. A. Kosasih,” *Bulletin of the National Museum of Ethnology*, *20*(2): 349-367.

Kosasih, R. A. (1975). *Ramayana A. B. C.* Bandung: Erlina.

*Reamker*. (1964), Phnom Penh: Buddhist Institute.

Sears, Lorie J. (1986). *Text and Performance in Javanese Shadow Theater: Changing Authorities in an Oral Tradition.* Doctoral dissertation, University of Wisconsin at Madison.

________. (1996). *Shadows of Empire: Colonial Discourse and Javanese Tales*. Durham: Duke University Press.

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង